# ព្រហ្មចារី (ពាក្យ៨)

-ឱព្រហ្មចារីស្រីវ័យក្រមុំ ថ្ងៃដែលបងសុំមាសមុំរៀបការ
ម្ដាយអូនបង្គាប់ជាប្រាក់ដុល្លារ ថ្លៃណាស់ជីវាបងគ្មានគ្រប់ទេ ។
-ឱព្រហ្មចារីស្រីក្រមុំក្មេង ហាក់ជាហាងឆេងផ្សារលក់កេរ្ដិ៍មេ
គេទិញគេលក់តាមតែចិត្តគេ បងរេរិះគិតសែនអនិចារ ។
-ឱព្រហ្មចារីស្រីស្មើក្រមុំ ថ្លៃណាស់ស្រីមុំម្ដាយអូនគាត់ថា
តែអូនឥតស្ដាយផ្ដាច់ឱ្យសង្សារ បំពេញតណ្ហាដោយឥតគិតថ្លៃ ។
-ឱព្រហ្មចារីស្រីមាសបងអើយ ម្ដេចឡើយឱ្យគេផុយម្លេះចរណៃ
ផ្គាប់ចិត្តគេជួញដូរយកកម្រៃ កែច្នៃលៃលកយកជាដុល្លារ ។
-ឱព្រហ្មចារីដ៏ប្រពៃពិត មាសមិត្តអាណិតគិតពិចារណា
ឈប់លក់ដូរទិញដូចត្រីក្នុងផ្សារ កុំឱ្យសង្សារបំផ្លាញស្រីថ្មី ។
-ខ្ញុំនិយាយនេះមិនមែនបន្ទោស កុំដាក់ទោសខ្ញុំដែលនៅក្មេងខ្ចី
ព្រោះដ្បិតរូបខ្ញុំមិនមែនកវី អ្វីៗខ្ញុំស្ដីមិនមែនសប្បាយ ។
-អភ័យទោសផងបើមានខុសឆ្គង កុំសំពងខ្ញុំដែលបរិយាយ
ខ្ញុំកូនអ្នកស្រែរស់កម្សត់កាយ ខ្ញុំពោលព្រោះស្ដាយរសព្រហ្មចារីយ៍ ។

ហាងកាហ្វេ ថ្ងៃទី០៩ ធ្នូ ២០០៧